





# សំលាញ់ពីរនាក់

(បទបន្ទោលកាក)

មើលអាសំលាញ់ ឯងទូន្មានឲ្យអញស្ម័គ្រ
តាមពុទ្ធវចនៈ នោះតើប្រសើរដូចម្ដេច។
វិសេសខាងត្រង់ មិនឲ្យគ្រងវង្គ្រងិច
រាជការសម្រេច តាមកិច្ចគតិទាំងបួន ។
ធ្វើជាមន្ត្រី ឲ្យតាំងមន្តបីខ្ជាប់ខ្ជួន
គតិទាំងបួន នេះខ្លួនកុំបង់មួយណា ។
ឯងចេះប្រសើរ ម្ដេចក៏មិនធ្វើរាជការ
បើធ្វើរាល់គ្នា អាណាធ្វើស្រែរកស៊ី ។
ឯងធ្វើនាម៉ឺន ឯអញក្រើនភាគទី
ធ្វើជាគូលី ម៉ែអញឪអញក៏ស្រួល ។
ឯងស្ដីនេះត្រូវ ប៉ុន្តែមិនសូវទំនួល
ឃើញតែខ្លួនស្រួល មិនឃើញប្រយោជន៍នគរ ។
រាជការរៀបចំ តាក់តែងថែទាំឲ្យល្អ
កំពុងតែក្រ មិនទាន់បង្កើតបានគ្រប់ ។
ទើបអញនេះណា ខំធ្វើរាជការថ្ងៃយប់
មិនមានធុញថប់ កៀចក្រាញនឹងកិច្ចនឹងការ ។
ដូច្នេះស្រុកយើង នឹងបានថ្កុំថ្កើងដោយសារ
កម្លាំងហត្ថា ហើយនឹងប្រាជ្ញាវៃវាង ។
ឯងមានស័ក្តិយស ថាអ្វីមិនខុសមិនល្អៀង
ធ្វើការព្រមព្រៀង នេះក៏ប្រពៃណាស់ហោង។
សូមឯងប្រដៅ ទូន្មានកូនចៅអញផង
ឲ្យតាមគន្លង គំនិតឯងគិតមូនមាំ ។
យើងមានសាលា មានគ្រូអាចារ្យនៅចាំ
ត្រួតត្រាថែទាំ ប្រដៅទូន្មានឲ្យចេះ ។
ម៉ែឪបណ្ដោយ កូនចៅនឹងផ្ដោយដោយធ្វេស
ឯងកុំប្រហែស តែខំគេជិះឯងអូស ។

**ម៉ុក សំឱក** (១៨៨០ - ១៩៣១)